FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ៤ លេខ ៣៤ ខែមីនា ឆ្នាំ ២០០៩

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

A Publication of the Cambodian Agricultural Research and Development Institute



# ប្រព័ន្ធនៃការសម្ងួតគ្រាប់ស្រូវ

## I. សេចក្តីផ្តើម

ស្រូវត្រូវបានគេច្រូតកាត់នៅអត្រាសំណើមគ្រាប់ចន្លោះពី ២០-៣០% (គោលការណ៍សើម)។ ការពន្យាពេលក្នុងការសម្ងួត ការសម្ងួតមិនពេញលេញ ឬការសម្ងួតមិនសព្វ នឹងបណ្តាលអោយមានការបាត់បង់ទាំងគុណភាព និងបរិមាណរបស់គ្រាប់ស្រូវ។

☆ **បច្ចេកទេសសម្ងួតគ្រាប់ស្រូវមិនល្អ ឬអន់ លទ្ធផលធ្វើអោយៈ**

- គ្រាប់អង្ករពណ៌លឿង ឬ សម្បុរស្រអាប់បណ្តាលមកពីកំណើមកំដៅ តាមរយៈដំណាកដង្ហើម (សំណើមខ្ពស់) ដែលបង្កជំងឺផ្សិត។
- អត្រាអង្ករសរដើមមានកំរិតទាប ដែលបណ្តាលមកពីសីតុណ្ហភាពស្រូវខ្ពស់ និងស្រូវស្ងួតហើយសើមៗ។
- អត្រាដំណុះមានកំរិតទាប និងកំលាំងលូតលាស់ខ្សោយ បណ្តាលមកពីស្រូវមានអត្រាសំណើមនិង កំដៅខ្ពស់ដែលធ្វើអោយកើតជំងឺផ្សិត និងសកម្មភាពរបស់ពពួកសត្វល្អិតផ្សេងៗទៀត ហើយអត្រាកំដៅនោះលើសពី ៤០% នៅពេលដែលយើងទុកដាក់មិនបានសមស្រប។
- ស្រូវរងការខូចខាត ដោយសារសកម្មភាពកើនឡើងរបស់សត្វល្អិត នៅពេលដែលគ្រាប់ស្រូវមានអត្រាសំណើមគ្រាប់ខ្ពស់។

## II. វិធីសាស្ត្រហាលសម្ងួត

### ១. ការសម្ងួតដោយពន្លឺថ្ងៃ (Sun Drying)

ការសម្ងួតដោយពន្លឺថ្ងៃ គឺជាវិធីសាស្ត្រសម្ងួតដែលមានការនិយមជាខ្លាំងនៅក្នុងអាស៊ី។

-មានតំលៃថោក

-តម្រូវការកំលាំងពលកម្មច្រើន

-មានភាពលំបាកក្នុងការត្រួតពិនិត្យសីតុណ្ហភាព។



### ២. ការសម្ងួតនៅអំឡុងពេលទុកដាក់ (In-store Drying)

គ្រាប់ស្រូវដែលមានអត្រាសំណើមគ្រាប់ទាបជាង ១៨% អាចសម្ងួតដោយប្រើរយៈពេលយឺតៗ នៅក្នុងបរិក្ខាទុកដាក់ដោយប្រើប្រាស់ខ្យល់ផ្លុំដែលមានកំដៅទាប (សីតុណ្ហភាពខ្ពស់ជាងខ្យល់បរិយាកាស ៣-៦ $^{0}$C)។

**ការសម្ងួតនៅក្នុងពេលទុកដាក់អាចធ្វើបានសម្រាប់ៈ**

-កម្រិតកសិដ្ឋាន ឬពាណិជ្ជកម្ម

-សមត្ថភាពសម្ងួតអាស្រ័យលើសំណង់អាគាសម្រាប់ទុកដាក់

-ពេលវេលាសម្ងួតចាប់ពី ២ ទៅច្រើនសប្តាហ៍

-គ្រាប់ស្រូវមានគុណភាពល្អ

-ប្រើប្រាស់ថាមពលតិច

-ប្រើប្រាស់ជាការសម្ងួតដំណាក់កាលទី២

-ពេលវេលាសម្ងួតមានរយៈពេលវែង



## ៣.ការសម្ងួតដោយខ្យល់ក្តៅ (Heated Air Drying )

### ឧបករណ៍សម្ងួតប្រភេទអចល័ត (Fixed bed batch dryer)




-សម្រាប់កសិករ,អ្នកទទួលម៉ៅការសម្ងួត, រោងម៉ាស៊ីនកិនស្រូវធន់តូច

-សមត្ថភាពផ្ទុកគ្រាប់ធញ្ញជាតិពី ១-១០តោន/ធុង

-ពេលវេលាសម្ងួតពី ៦-៨ម៉ោង

-ងាយស្រួល និងមានតម្លៃថោក

-អាចធ្វើការផ្លាស់ប្តូរទៅតាមតំបន់

-ការសម្ងួតមិនសព្វល្អ

-តម្រូវការកំលាំងពលកម្មច្រើន

### ម៉ាស៊ីនសម្ងួតគ្រាប់មានចលនាសារចុះឡើង (Re-circulating Batch Dryer)

-ម៉ាស៊ីនសម្ងួតប្រភេទនេះសមស្រប សម្រាប់រោងម៉ាស៊ីន និងសហគ្រាស



-សមត្ថភាពផ្ទុកគ្រាប់ពី ៤-១០តោន/ធុង

-រយៈពេលនៃការសម្ងួតគឺ ៦-៨ម៉ោង

-ការសម្ងួតមានភាពសព្វល្អ

-ប្រព័ន្ធត្រួតពិនិត្យស្វ័យប្រវត្តិ

### ម៉ាស៊ីនសម្ងួតគ្រាប់ស្រូវមានចលនាបន្តរគ្នា (Continuous Flow Dryer)

-ឧបករណ៍នេះសម្ងួតប្រភេទនេះទាមទាសំណង់ឃ្លាំងធំ សម្រាប់ទុកដាក់

-សមត្ថភាពសម្ងួតដល់ ១០តោន/ម៉ោង

-អត្រាសម្ងួត១-២%/ម៉ោង

-ប្រព័ន្ធត្រួតពិនិត្យស្វ័យប្រវត្តិ

-តម្រូវការទុនវិនិយោគច្រើន

-តម្រូវការគ្រាប់ច្រើនក្នុងពេលសម្ងួតម្តងៗ



## III.គោលការណ៍ណែនាំ

- ត្រូវធ្វើការសម្អាតគ្រាប់ស្រូវមុនពេលសម្ងួត ដើម្បីជាសវាងការសម្ងួតមិនសព្វល្អ ។
- ត្រូវធ្វើការសម្ងួតភ្លាមៗបន្ទាប់ពីច្រូតកាត់ស្រូវរហូតដល់អត្រាសំណើមទាបជាង១៨% (ការសម្ងួតដំបូង) ។ សំណើមនេះអាចទុកដាក់គ្រាប់ដោយសុវត្ថិភាពបានក្នុងរយៈពេលពីរសប្តាហ៍ ។
- ការសម្ងួតសម្រាប់ការកិនបំលែង មានលក្ខណៈសមស្របនៅអត្រាសំណើមគ្រាប់ ១៤% ។ កាលណាសម្ងួតទាបជាង ១៤% ធ្វើអោយមានការបាត់បង់ទំងន់គ្រាប់ និងទិន្នផលដែលទទួលបានពីការកិនទាប ។
- ការទុកដាក់រយៈពេល ៨ ដល់ ១២ខែ មានលក្ខណៈសមស្របសម្រាប់គ្រាប់ស្រូវមានអត្រាសំណើម ១៣% ឬទាបជាងនេះ ។ ចំពោះការទុកដាក់ ស្រូវរយៈពេលយូរជាងមួយឆ្នាំ ត្រូវសម្ងួតគ្រាប់ស្រូវរហូតដល់សំណើម ៩-១០% ។
- មិនត្រូវលាយច្របល់គ្រាប់ស្រូវដែលមានអត្រាសំណើមខុសៗគ្នាឡើយ ។ ព្រោះដើម្បីជាសវាងការបាត់បង់គុណភាពគ្រាប់ ។
- ត្រួតពិនិត្យសីតុណ្ហភាពគ្រាប់ និងសំណើមគ្រាប់ស្រូវ ដើម្បីការពារការសម្ងួតលើសកំណត់ ។


សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យវិស្វកម្មកសិកម្ម មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ.

ទូរស័ព្ទលេខៈ (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ | ទូរអក្សរៈ cardi@cardi.org.kh | វែបសាយៈ www.cardi.org.kh

Sbunna@cardi.org.kh | TRIN@cardi.org.kh | HUNYADANA@cardi.org.kh